ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ឯកសារណែនាំប្រតិបត្តិស្តីពី

# បណ្ណាល័យបឋមសិក្សា



## ផ្នែក២៖ សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ

ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៤១៦ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ ឯកសារណែនាំប្រតិបត្តិស្តីពី បណ្ណាល័យបឋមសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រកាសលេខ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ អគ្គនាយកដ្ឋានអប់រំ
- យោងសេចក្តីសម្រេចលេខ១១ អយក.សសរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ ឯកសារណែនាំប្រតិបត្តិស្តីពី បណ្ណាល័យបឋមសិក្សា។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

ឯកសារណែនាំប្រតិបត្តិស្តីពី បណ្ណាល័យបឋមសិក្សា មាន៣ផ្នែករួមមាន៖

- ផ្នែកទី១. ការបង្កើតនិងគ្រប់គ្រងបណ្ណាល័យ
- ផ្នែកទី២. សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ
- ផ្នែកទី៣. បញ្ជីសៀវភៅរឿងកុមារ។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃ អគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានបឋមសិក្សា ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងប្រធាននាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត គ្រប់គ្រឹះស្ថានបឋមសិក្សា ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០២១

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលរាជធានី ខេត្ត

  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ៤

  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នា.បឋមសិក្សា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## គណៈកម្មការគ្រប់គ្រង និងត្រួតពិនិត្យ

| | | | | |
|---|---|---|---|---|
| ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហង់ជួន** | **ណារ៉ុន** | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ប្រធាន |
| ឯកឧត្តមបណ្ឌិតសភាចារ្យ | **ណាត** | **ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួង អ.យ.ក. | អនុប្រធាន |
| លោកជំទាវ | **ទន់** | **សាអ៊ីម** | អនុរដ្ឋលេខាធិការក្រសួង អ.យ.ក. | សមាជិក |
| ឯកឧត្តម | **ពុត** | **សាមិត្ត** | អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ឯកឧត្តមបណ្ឌិត | **ចាន់** | **សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា | សមាជិក |
| លោក | **ស៊ុន** | **ប៊ុណ្ណា** | ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | សមាជិក |
| លោក | **ម៉ៅ** | **ម៉េងឡុង** | ប្រធាននាយកដ្ឋាន ប.វ. | សមាជិក |
| លោក | **ជា** | **វ៉ាន់ថា** | ប្រធានអង្គការរូមធូរីដប្រចាំកម្ពុជា | សមាជិក |
| លោក | **ហុក** | **សុទ្ធិ** | ប្រធានអង្គការស៊ីប៉ាប្រចាំកម្ពុជា | សមាជិក |

## គណៈកម្មការបច្ចេកទេស និងចងក្រង

| | | | |
|---|---|---|---|
| ឯកឧត្តមបណ្ឌិត | **ចាន់** | **សុភា** | ប្រធាននាយកដ្ឋានបឋមសិក្សា |
| លោក | **តុង** | **បូរិទ្ធ** | អនុប្រធាននាយកដ្ឋានបឋមសិក្សា |
| លោក | **ភាន់** | **ពុទ្ធី** | អនុប្រធាននាយកដ្ឋានបឋមសិក្សា |
| លោក | **យិន** | **ធី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោកស្រី | **ថោង** | **ច័ន្ទដារ័ណ** | ប្រធានការិយាល័យ នាយកដ្ឋានបឋមសិក្សា |
| លោក | **ម៉ុក** | **រ៉ាស៊ី** | ប្រធានការិយាល័យ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក | **ឈួន** | **គ្រី** | អនុប្រធានការិយាល័យ នាយកដ្ឋានបឋមសិក្សា |
| លោក | **ឈាង** | **ស៊ីម** | អនុប្រធានការិយាល័យ នាយកដ្ឋាន ប.វ. |
| កញ្ញា | **អយ** | **សុគន្ធា** | មន្ត្រីនាយកដ្ឋានបឋមសិក្សា |
| លោក | **ហ៊ិន** | **ឡាច** | មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក | **ហោ** | **សុខៈ** | នាយកកម្មវិធីអំណានអង្គការរូមធូរីដកម្ពុជា |
| លោក | **ចាន់** | **សុខអៀង** | ប្រធានជាន់ខ្ពស់កម្មវិធីអំណានអង្គការរូមធូរីដកម្ពុជា |
| លោក | **ឡេង** | **សូឡី** | ប្រធានកម្មវិធីអំណានអង្គការរូមធូរីដកម្ពុជា |
| លោក | **ស៊ិន** | **សុធា** | ប្រធានកម្មវិធីបណ្ណាល័យអង្គការស៊ីប៉ា |

## ការីកុំព្យូទ័រ

| | | | |
|---|---|---|---|
| លោក | **ហុង** | **ពិដោរ** | អនុប្រធានការិយាល័យ នាយកដ្ឋានបឋមសិក្សា |
| លោក | **សេង** | **ពិសិដ្ឋ** | មន្ត្រីនាយកដ្ឋានបឋមសិក្សា |
| លោក | **យូ** | **ប៊ុនហាន** | មន្ត្រីជាន់ខ្ពស់កម្មវិធីអំណានអង្គការរូមធូរីដកម្ពុជា |

# មាតិកា


**អារម្ភកថា** ........ 6

**អ្នកប្រើប្រាស់ឯកសារនេះ** ........ 7

**គោលបំណងនៃការចងក្រងឯកសារ** ........ 7

I. **ម៉ោងបណ្ណាល័យ** ........ 8

១) ការជ្រើសរើសម៉ោង សម្រាប់ធ្វើជាម៉ោងបណ្ណាល័យ ........ 8

២) រយៈពេល និងសកម្មភាពម៉ោងបណ្ណាល័យ ........ 8

II. **អំណានឮ** ........ 10

១) និយមន័យ ........ 10

២) គោលបំណង ........ 10

៣) ដំណើរការសកម្មភាពអំណានឮ ........ 10

III. **អំណានចូលរួម** ........ 16

១) និយមន័យ ........ 16

២) គោលបំណង ........ 16

៣) ដំណើរការសកម្មភាពអំណានចូលរួម ........ 16

IV. **អំណានដៃគូ** ........ 23

១) និយមន័យ ........ 23

២) គោលបំណង ........ 23

៣) ដំណើរការសកម្មភាពអំណានដៃគូ ........ 23

V. **អំណានបុគ្គល** ........ 28

១) និយមន័យ ........ 28

២) គោលបំណង ........ 28

៣) ដំណើរការសកម្មភាពអំណានបុគ្គល ........ 28

# អារម្ភកថា

បណ្ណាល័យមួយដែលបង្កើតឡើងហើយមានដំណើរការល្អ លុះត្រាតែមានសម្ភារបរិក្ខារ សៀវភៅ ឯកសារ និងសម្ភារៈចាំបាច់ផ្សេងទៀតសមស្រប។ មិនតែប៉ុណ្ណោះ បណ្ណាល័យត្រូវតែមានបណ្ណារក្សប្រចាំការ មានសកម្មភាពខ្ចី-សង និងសកម្មភាពអំណានជាប្រចាំ។ ដើម្បីមានសកម្មភាពអំណានជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព គ្រូប្រចាំថ្នាក់ដែលជាអ្នកដឹកនាំសកម្មភាពអំណាន ត្រូវតែយល់ដឹងអំពីប្រភេទនិងដំណាក់កាលនៃសកម្មភាពអំណាន នៅក្នុងម៉ោងបណ្ណាល័យ។

ឯកសារណែនាំប្រតិបត្តិស្តីពីបណ្ណាល័យបឋមសិក្សា ក្នុងផ្នែកទី២ បង្ហាញអំពី "សកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ"។ ឯកសារផ្នែកទី២នេះ នឹងបង្ហាញជូនអ្នកប្រើប្រាស់អំពីប្រភេទនៃអំណានទាំង ៤ រួមមាន អំណានឮ អំណាចូលរួម អំណានដៃគូ និងអំណានបុគ្គល។ ចំពោះផ្នែកនៃប្រភេទអំណាននីមួយៗ មានបង្ហាញជូនអំពីនិយមន័យ គោលបំណង និងដំណើរការសកម្មភាពអំណាន។ ក្នុងដំណើរការសកម្មភាពអំណាន មានរំលេចលំនាំគោលនៃសកម្មភាពអំណាន និងលំនាំលម្អិតនៃកម្មភាពអំណាន ដែលមានសកម្មភាពភាពតូចៗ និងការកំណត់រយៈពេលនៃកម្មភាពនីមួយៗ ដើម្បីឱ្យគ្រូដឹកនាំអំណានងាយស្រួលក្នុងការគ្រប់គ្រងដឹកនាំដំណើរការអាន និងពេលវេលាអាន។

ក្រុមការងារចងក្រងសេចក្តីណែនាំរបស់ក្រសួង ដែលដឹកនាំដោយនាយកដ្ឋានបឋមសិក្សាសហការជាមួយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ អង្គការរូមធូរីដ អង្គការស៊ីប៉ា សង្ឃឹមថា សេចក្តីណែនាំនេះ នឹងបានជាឯកសារជំនួយស្មារតីដ៏សំខាន់មួយ សម្រាប់គណៈគ្រប់គ្រងសាលា បណ្ណារក្ស លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ ក្នុងការដឹកនាំគ្រប់គ្រង ចាត់ចែងឱ្យមានសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យកាន់តែផុលផុស ក្នុងន័យឈានទៅបណ្តុះទម្លាប់អាន ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអានពេញមួយជីវិត។

គណៈកម្មការរៀបរៀង

## អ្នកប្រើប្រាស់ឯកសារនេះ

អ្នកពាក់ព័ន្ធដែលត្រូវប្រើប្រាស់ឯកសារនេះ មានដូចខាងក្រោម៖

- ក្រសួងអប់រំ យុវជន និងកីឡា
- បណ្ណារក្សនៅតាមសាលាបឋមសិក្សា
- គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូនៅតាមសាលាបឋមសិក្សា
- អង្គការដៃគូអភិវឌ្ឍនានា
- សហគមន៍ ក្រុមប្រឹក្សាកុមារ និងសិស្សានុសិស្សទាំងអស់

## គោលបំណងនៃការចងក្រងឯកសារ

ឯកសារនេះមានគោលបំណងជួយគាំទ្រដល់លោកគ្រូ អ្នកគ្រូ ពីរបៀបចាត់ចែងឱ្យសិស្សនៅសាលាបឋមសិក្សាមានទម្លាប់អានដូចជា៖

- ផ្តល់គោលគំនិតទូទៅឬកញ្ចក់ឆ្លុះបញ្ចាំងដល់សាលាអំពីកម្រិតដំណើរការបណ្ណាល័យនៅតាមសាលារៀងៗខ្លួន
- បង្ហាញពីរបៀបកៀរគរសហគមន៍ឱ្យចូលរួមបង្កើតនិងគ្រប់គ្រងបណ្ណាល័យនៅតាមសាលា
- ណែនាំអំពីវិធីសាស្ត្រអំណានផ្សេងគ្នា ដើម្បីជួយគ្រូប្រចាំថ្នាក់ឱ្យដឹកនាំសកម្មភាពអំណានក្នុងន័យទាក់ទាញសិស្សានុសិស្សឱ្យចូលរួម និងចូលចិត្តអាន
- ជួយសិស្សក្នុងការបណ្តុះទម្លាប់អាន មានបំណិនក្នុងការអាន និងបន្តអានពេញមួយជីវិត។

## I. ម៉ោងបណ្ណាល័យ

គណៈគ្រប់គ្រងសាលា ឬ បណ្ណារក្ស ត្រូវប្រាកដថា **ថ្នាក់នីមួយៗមានម៉ោងបណ្ណាល័យយ៉ាងតិច ១ម៉ោងសិក្សា ក្នុង១សប្តាហ៍**។ បណ្ណាល័យ ក៏ត្រូវបើកដំណើរការក្នុងម៉ោងដែលសិស្សសម្រាកចេញលេងផងដែរ ព្រោះជាពេលវេលាដ៏សំខាន់សម្រាប់សិស្សចូលធ្វើសកម្មភាពអាន ប្រើប្រាស់បណ្ណាល័យ និងអាចខ្ចី-សងសៀវភៅ។

ម៉ោងបណ្ណាល័យ និងម៉ោងអំណានសេរី ត្រូវបានដាក់បញ្ចូលក្នុងតារាងកាលវិភាគបណ្ណាល័យ ដែលដាក់តាំងបង្ហាញក្នុងបណ្ណាល័យ។ សកម្មភាពអានក្នុងម៉ោងបណ្ណាល័យ និងម៉ោងអំណានសេរី គឺត្រូវកើតឡើងក្នុងគោលបំណងអភិវឌ្ឍទម្លាប់អាន ជាជាងអភិវឌ្ឍបំណិនអាន។

ក្រៅពីម៉ោងបណ្ណាល័យ និងម៉ោងអំណានសេរី កាលវិភាគបណ្ណាល័យត្រូវរៀបចំម៉ោងសម្រាប់សកម្មភាពរៀបចំ និងថែទាំបណ្ណាល័យផងដែរ។ កាលវិភាគបណ្ណាល័យ ត្រូវរៀបចំជាពីរប្រភេទ គឺប្រចាំខែ និងប្រចាំសប្តាហ៍។ បណ្ណារក្សត្រូវរៀបចំបង្កើតកាលវិភាគទាំងពីរនេះ និងតាំងបង្ហាញនៅក្នុងបណ្ណាល័យ។

### ១) ការជ្រើសរើសម៉ោង សម្រាប់ធ្វើជាម៉ោងបណ្ណាល័យ

គោលបំណងនៃបណ្ណាល័យបឋមសិក្សាគឺ បណ្តុះទម្លាប់អានដល់សិស្ស។ គ្រូប្រចាំថ្នាក់ មានតួនាទីដ៏សំខាន់ក្នុងការដឹកនាំសិស្សរបស់ខ្លួនចូលអនុវត្តសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ។ ម៉ោងបណ្ណាល័យបានជួយគាំទ្របន្ថែមទៀតដល់សិស្ស ក្នុងការសិក្សានៅក្នុងម៉ោងភាសាខ្មែរ។ គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូ និងបណ្ណារក្ស អាចកំណត់យក១ម៉ោងសិក្សានៃម៉ោងសិក្សាសង្គម ឬម៉ោងណាមួយ មកធ្វើជាម៉ោងបណ្ណាល័យ និងអាចបត់បែនក្នុងការរៀបចំកាលវិភាគសម្រាប់ថ្នាក់នីមួយៗគ្រប់កម្រិត។

### ២) រយៈពេល និងសកម្មភាពម៉ោងបណ្ណាល័យ

ម៉ោងបណ្ណាល័យ មានរយៈពេល៤០នាទីដូចម៉ោងសិក្សាក្នុងថ្នាក់រៀនដែរ។ ជាទូទៅ រយៈពេលនេះគ្រូប្រចាំថ្នាក់ត្រូវដឹកនាំសិស្សធ្វើសកម្មភាពអំណាននៅក្នុងបណ្ណាល័យ។ ករណីសាលារៀនធំមានចំនួនថ្នាក់ច្រើន គណៈគ្រប់គ្រងសាលា ឬ បណ្ណារក្ស ត្រូវលើកទឹកចិត្តគ្រូប្រចាំថ្នាក់ធ្វើសកម្មភាពអំណាន នៃម៉ោងបណ្ណាល័យ នៅក្នុងបន្ទប់ រៀនរបស់ខ្លួន ដើម្បីផ្តល់ឱកាសដល់ថ្នាក់នីមួយៗមានម៉ោងបណ្ណាល័យរបស់ខ្លួន ១ម៉ោងសិក្សា/១សប្តាហ៍។ ក្នុងម៉ោងបណ្ណាល័យ គ្រូប្រចាំថ្នាក់ ត្រូវដឹកនាំសិស្សធ្វើសកម្មភាពដូចខាងក្រោម៖

- សកម្មភាពអំណាន (២៥ - ៣០ នាទី)
- ការខ្ចីសៀវភៅទៅអាននៅផ្ទះ (៧ - ១០ នាទី)

#### ក) សកម្មភាពអំណាន

បណ្ណាល័យ គឺជាកន្លែងដ៏សំខាន់មួយសម្រាប់សិស្សអានប្រកបដោយភាពរីករាយ និងអភិវឌ្ឍទម្លាប់អាន។ ទម្លាប់អាន គឺជាការអានដែលធ្វើឡើងដោយស្ម័គ្រចិត្ត និងញឹកញាប់។ ទម្លាប់អានកើតឡើងដោយសារតែកុមារបានផ្សារភ្ជាប់ទៅនឹងអត្ថបទ។ កុមារនឹងចូលចិត្តអាន នៅពេលពួកគេអាចអាននូវអ្វីដែលពួកគេចង់អាន និងមិនស្ថិតនៅក្រោមសម្ពាធក្នុងការអានឱ្យបានចងចាំ និង ត្រឹមត្រូវ។

ឯកសារនេះ ផ្តល់ជូននូវសកម្មភាពអំណានចំនួន៤ ដើម្បីឱ្យកុមារមានភាពរីករាយជាមួយការអាន និងអានដោយគ្មានសម្ពាធដែលជាកត្តាសំខាន់ក្នុងការចូលរួមអភិវឌ្ឍទម្លាប់អានដល់ពួកគេ។ សកម្មភាពអំណានទាំង៤នេះរួមមាន **អំណានឮ អំណានចូលរួម អំណានដៃគូ និងអំណានបុគ្គល។** លើសពីការអភិវឌ្ឍទម្លាប់អានអំណានទាំង៤ ក៏ជួយឱ្យកុមារអភិវឌ្ឍបំណិនអានផងដែរ។ តាមការសិក្សាស្រាវជ្រាវជាច្រើនបង្ហាញថា កុមារនឹងរៀនលំនាំអានតាមគ្រូ បន្ទាប់ពីពួកគេបានស្តាប់ និងចូលរួមអានជាមួយគ្រូក្នុងម៉ោងបណ្ណាល័យ។

### ខ) ការខ្ចីសៀវភៅទៅអាននៅផ្ទះ

បន្ទាប់ពីសកម្មភាពអំណានត្រូវបានបញ្ចប់ក្នុងរយៈពេលចន្លោះពី ២៥ ទៅ ៣០នាទី គ្រូប្រចាំថ្នាក់ត្រូវលើកទឹកចិត្តសិស្សឱ្យខ្ចីសៀវភៅទៅអាននៅផ្ទះ ទៅតាមកម្រិតអានរបស់ពួកគេ។ សកម្មភាពខ្ចី-សងសៀវភៅនេះ មានរយៈពេលពី ៧ ទៅ ១០នាទី ដែលដឹកនាំដោយបណ្ណារក្ស និងមានការជួយគាំទ្រពីគ្រូប្រចាំថ្នាក់ ក្នុងការកត់ត្រាការខ្ចី-សង។

**ខ្លឹមសារទាំងមូលខាងក្រោមនេះ មានលម្អិតអំពីដំណើរការសកម្មភាពអំណានសំខាន់ទាំង៤៖**

## II. អំណានឮ

### ១) និយមន័យ

អំណានឮគឺជាសកម្មភាព ដែលគ្រូប្រចាំថ្នាក់ជ្រើសរើសសៀវភៅរឿងមួយដែលមានទំហំសមល្មមនិង មានកម្រិតអានត្រូវតាមឬខ្ពស់ជាងសមត្ថភាពសិស្សរបស់ខ្លួន មកធ្វើសកម្មភាពអានស្ទាត់ជំនាញជាគំរូទៅកាន់សិស្ស ។ គ្រូលើកដាក់សំឡេង មានកាយវិការទាក់ទាញតាមខ្លឹមសាររឿងខ្លះៗ ប្រកបដោយភាពរីករាយ និងលើកទឹកចិត្តសិស្ស។ សកម្មភាពអំណានឮនេះ ត្រូវបានលើកទឹកចិត្តឱ្យធ្វើញឹកញាប់ជាមួយក្រុមសិស្សថ្នាក់ទី១-៣ ច្រើនជាងក្រុមសិស្សថ្នាក់ទី៤-៦។

### ២) គោលបំណង

- លើកទឹកចិត្ត និងធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការអាន
- ផ្តល់ជាគំរូល្អនៃការអានស្ទាត់ជំនាញ
- ណែនាំប្រភេទផ្សេងៗគ្នានៃរឿងដល់សិស្ស
- លើកកម្ពស់ទម្លាប់នៃការអាន។

### ៣) ដំណើរការសកម្មភាពអំណានឮ

### ក) លំនាំគោលនៃការធ្វើសកម្មភាពអំណានឮ

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅត្រូវតាមកម្រិត ឬខ្ពស់ជាងកម្រិតអានរបស់កុមារ |

#### ក-១) ដំណាក់កាលត្រៀម មុនពេលធ្វើសកម្មភាពអំណាន

៥-៧ នាទី | ក្រុមធំ

ការស្វាគមន៍ដល់សិស្សដែលបានមកបណ្ណាល័យ។

1. ឱ្យកុមារដើរមើល និងអានសម្ភារព្រីនរីច
2. គ្រូជ្រើសរើសសៀវភៅ១ក្បាល ហើយអាន១ចប់
3. កំណត់ពីកន្លែងដែលត្រូវសួរសំណួរទស្សន៍ទាយ ២ទៅ៣សំណួរ
4. កំណត់ពាក្យថ្មី ១ទៅ៣ពាក្យ ដើម្បីណែនាំ
5. រំឮកដល់សិស្សពីគោលការណ៍បណ្ណាល័យ និងកម្រិតសៀវភៅ។

#### ក-២) មុនពេលអាន

៣-៥ នាទី | ក្រុមធំ

1. បង្ហាញក្របសៀវភៅ

2a. សួរសំណួរអំពីរូបភាពនៅលើក្រប

- **តើអ្នកទាំងអស់គ្នា ឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ?**
- **តើអ្នកឃើញមាន.......ប៉ុន្មាន?**

- **តើពួកគេកំពុងធ្វើអ្វី?**
- **តើអ្នកគិតថា នរណាខ្លះជាតួអង្គនៅក្នុងរឿងនេះ?**

2b. សួរសំណួរផ្សារភ្ជាប់រូបភាពទៅនឹងជីវភាពរស់នៅរបស់កុមារ

- **តើអ្នកធ្លាប់ឃើញ.................ដែរឬទេ?**
- **តើនៅផ្ទះអ្នកមាន....................ដែរឬទេ?**
- **តើ......ធ្លាប់មានអ្វីកើតឡើងដល់អ្នកទេ?**

2c. សួរសំណួរទស្សន៍ទាយ ១ទៅ២សំណួរ

- **តើអ្នកគិតថានឹងមានអ្វីកើតឡើងនៅក្នុងរឿងនេះ?**
- **តើអ្នកគិតថាតួអង្គទាំងនេះនឹងធ្វើអ្វី?**

3. សួរ១ទៅ២សំណួរអំពីរូបភាពនៅលើទំព័រដំបូង (ប្រសិនបើរូបភាពគួរឱ្យចាប់អារម្មណ៍)
4. ណែនាំអំពីសៀវភៅ (អានចំណងជើង ឈ្មោះអ្នកនិពន្ធ ឈ្មោះអ្នកគូរគំនូរ)
5. ណែនាំពាក្យថ្មី ១ទៅ៣ពាក្យ។

**ក-៣) ពេលអាន** ១០-១៥ នាទី | ក្រុមធំ

1. អានរឿងយឺតៗ និងច្បាស់ៗ ដោយលើកដាក់សំឡេង និងកាយវិការតាមខ្លឹមសាររឿង។
2. បង្ហាញខ្លះៗអំពីរូបភាពសំខាន់ៗនៅក្នុងរឿង។
3. សួរសំណួរទស្សន៍ទាយ២ទៅ៣សំណួរ៖ តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ទៅទៀត?

**ក-៤) ក្រោយពេលអាន** ៤-៧ នាទី | ក្រុមធំ

1. សួរសំណួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង៖ **នរណា? អ្វី? កន្លែងណា? ពេលណា?**
2. រំឭកឡើងវិញអំពីផ្នែកសំខាន់ៗនៃរឿង៖ **តើមានអ្វីបានកើតឡើងដំបូងនៅក្នុងរឿងនេះ? តើមានអ្វីកើតឡើងបន្ទាប់ទៀត? តើមានអ្វីកើតឡើងនៅចុងបញ្ចប់?**
3. សួរសំណួរ«ហេតុអ្វី» ងាយៗ ១ទៅ២សំណួរ៖ **ហេតុអ្វីបាន (តួអង្គ)..........(ធ្វើសកម្មភាព)?**
4. ឱ្យកុមារស្ម័គ្រចិត្តធ្វើត្រាប់តាមកាយវិការ និងធ្វើសំឡេងត្រាប់តាមតួអង្គក្នុងរឿងខ្លះៗ។

*ប្រសិនបើសល់ពេលឱ្យកុមារបន្តធ្វើសកម្មភាព៖*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬ ខ្ទីសៀវភៅ*

## ខ) លំនាំលម្អិតនៃការធ្វើសកម្មភាពអំណានឮ

## ខ-១) ដំណាក់កាលត្រៀម មុនពេលធ្វើអំណាន

៥-៧ នាទី | ក្រុមធំ

1. <u>កិច្ចស្វាគមន៍ និងការណែនាំ</u>

   នៅពេលដែលសិស្សចូលដល់បណ្ណាល័យ គ្រូត្រូវណែនាំពួកគេឱ្យអង្គុយលើឥដ្ឋពីមុខអ្នក។ គ្រូអង្គុយលើកៅអី និងនិយាយទៅកាន់សិស្ស៖

   *"សូមស្វាគមន៍ដល់អ្នកទាំងអស់គ្នាដែលបានមកបណ្ណាល័យ។ មុនចាប់ផ្តើមស្តាប់គ្រូអានរឿង អ្នកទាំងអស់ក្រោកឈរ ហើយដើរអានសម្ភារព្រីនរីចដែលតាំងនៅក្នុងបណ្ណាល័យ និងសូមត្រឡប់មកអង្គុយទីនេះវិញ នៅពេលគ្រូហៅ។"*

2. <u>ជ្រើសរើសសៀវភៅ១ក្បាល ហើយអាន</u>

   ពេលសិស្សដើរអានព្រីនរីច គ្រូជ្រើសរើសសៀវភៅ១ក្បាល ហើយអានយ៉ាងហោចណាស់ឱ្យបាន១ចប់ មុនពេលអ្នកអានជាមួយសិស្ស ព្រោះអ្នកចាំបាច់ត្រូវយល់សាច់រឿងជាមុន។

   សៀវភៅដែលជ្រើសរើសមកអានក្នុងម៉ោងនេះ គួរតែជាប្រភេទសៀវភៅដែលខុសគ្នាជាមួយសៀវភៅដែលបានអានកាលពីម៉ោងបណ្ណាល័យលើកមុន (ឧ.រឿងផ្សងព្រេង, រឿងអាថ៌កំបាំង ឬរឿងសប្បាយៗ)។ សិស្សគួរតែបានស្តាប់រឿងប្រភេទផ្សេងៗពីម៉ោងបណ្ណាល័យមួយទៅមួយទៀត។ គ្រូប្រចាំថ្នាក់ ត្រូវរៀបចំដើម្បី**<u>អានរឿង</u>** ជាជាង **<u>និទានរឿង</u>** តាមការចងចាំ។

3. <u>កំណត់ទំព័រ និងកន្លែងដែលត្រូវសួរសំណួរទស្សន៍ទាយ</u>

   កំណត់**២ - ៣ កន្លែង** នៅក្នុងសៀវភៅរឿង ដើម្បីសួរសំណួរទស្សន៍ទាយដោយដាក់ក្រដាស់ពណ៌ ឬសញ្ញាសំគាល់ត្រង់កន្លែងដែលត្រូវសួរ។ សំណួរទាំងនេះគួរតែនៅក្នុងរឿងត្រង់កន្លែងដែលនឹងមានអ្វីកើតឡើងបន្ទាប់ទៀត ដែលមិនច្បាស់លាស់។

4. <u>កំណត់ពាក្យថ្មីដើម្បីណែនាំ</u>

   ជ្រើសរើសពាក្យថ្មី **១ - ៣** ពាក្យ ពីក្នុងរឿងដើម្បីណែនាំដល់សិស្ស។ ប្រសិនបើអាចធ្វើបាន ការណែនាំពាក្យថ្មីនេះ ត្រូវប្រើរូបភាពក្នុងសៀវភៅ វត្ថុ ឬសកម្មភាព។ ត្រូវត្រៀមរៀបចំពន្យល់ន័យពាក្យប្រសិនបើអ្នកមិនអាចប្រើប្រាស់រូបភាព វត្ថុ ឬសកម្មភាពណាមួយបាន។

   សូមចងចាំថា ពាក្យដែលជ្រើសរើសគួរតែជាពាក្យថ្មី ដែលយើងគិត/សន្មត់ថា សិស្សមិនដែលធ្លាប់ដឹង។ ពាក្យទាំងនេះអាចជាពាក្យ ឬគំនិតដែលសិស្សមិនធ្លាប់ស្គាល់។ ឧទាហរណ៍ខ្លះៗនៃពាក្យថ្មីទាំងនោះដូចជា «ច្រឡំ» ឬ «ក្បួន» ដែលសិស្សមិនដឹងពីអត្ថន័យនៃពាក្យទាំងនេះ។ ពាក្យដូចជា «ទឹក» និង «គោ» គឺមិនគួរជ្រើសរើសទេ ព្រោះសិស្សភាគច្រើនបានស្គាល់ពាក្យ និងន័យរួចហើយ។

   ប្រសិនបើមានពាក្យពិបាកនៅក្នុងសៀវភៅដែលសិស្សមិនដឹងច្រើនជាង៣ពាក្យ សូមជ្រើសរើសយកតែ ៣ពាក្យ ដែលសំខាន់ជាងគេបំផុត និងអាចជួយសិស្សឱ្យយល់ពីខ្លឹមសាររឿង។

**<u>ដំណាក់កាលចាប់ផ្តើមធ្វើសកម្មភាពអំណានឮជាមួយសិស្ស</u>**

ហៅសិស្សមកជួបជុំគ្នាវិញ

DO គ្រូអង្គុយនៅលើកៅអី និងហៅសិស្សមកកន្លែងដើមវិញ។ សិស្សអង្គុយតាមសម្រួលជារាងស្នែងក្របី ជាជាងអង្គុយជាជួរ។ ឱ្យសិស្សអង្គុយជិតៗអ្នក តាមដែលអាចធ្វើបាន។ រំឭកពួកគេអំពីគោលការណ៍បណ្ណាល័យ (ពុំចាំបាច់ធ្វើរាល់ម៉ោងបណ្ណាល័យទេ)។ ប្រាប់សិស្សពីការចាប់ផ្តើមសកម្មភាពអំណាននេះ។ "**ថ្ងៃនេះយើងនឹងធ្វើសកម្មភាពអំណានញ**" ។

## ខ-២) មុនពេលអាន

៣-៥ នាទី | ក្រុមធំ

1. <u>បង្ហាញក្របសៀវភៅ</u>

ជាជម្រើស៖ បង្ហាញក្របសៀវភៅតែម្តង ឬយកក្រដាសបាំងចំណងជើងហើយបើកឃើតៗ។

គ្រូនិយាយ៖ "**ខ្ញុំចង់អានរឿងមួយឱ្យអ្នកទាំងអស់គ្នាស្តាប់**" ។

2a. <u>សួរសំណួរអំពីរូបភាពនៅលើក្របសៀវភៅ</u>

គ្រូនិយាយ និងសួរ៖ "**មើលរូបភាពនៅលើក្របមុខនៃសៀវភៅនេះ។ តើអ្នកទាំងអស់គ្នាឃើញអ្វីខ្លះ? តើមាន.....ប៉ុន្មាន? តើអ្នកគិតថា............កំពុងធ្វើអ្វី?**"

ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗខាងលើ។ គ្រូបន្តសួរ៖ "**តើអ្នកគិតថានរណាជាតួអង្គសំខាន់នៃរឿងនេះ?**" ទទួលចម្លើយ២ទៅ៣នាក់។

(សម្រាប់សិស្សថ្នាក់ទី១, អំឡុងពេល២ទៅ៣ម៉ោងបណ្ណាល័យដំបូង អ្នកអាចប្រាប់សិស្សតែម្តង ប្រសិនបើសង្កេតឃើញថា សិស្សលំបាកចូលរួមជាមួយសំណួរទាំងនេះ)។

2b. <u>សួរសំណួរផ្សារភ្ជាប់រូបភាពទៅនឹងជីវភាពរស់នៅរបស់កុមារ</u>

គ្រូសួរ៖ "**តើអ្នកធ្លាប់ឃើញ.........? តើនៅផ្ទះប្អូនមាន.........ដែរឬទេ?**"

ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗ។

2c. <u>សួរសំណួរទស្សន៍ទាយខ្លឹមសាររឿង ២ទៅ៣ សំណួរ</u>

គ្រូសួរ៖ "**តើអ្នកគិតថានឹងមានអ្វីកើតឡើងនៅក្នុងរឿងនេះ? តើអ្នកគិតថាតួអង្គ...នេះនឹងធ្វើអ្វី?**"

ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗ។

3. <u>សួរ១ទៅ២សំណួរអំពីរូបភាពនៅទំព័រដំបូង</u>

ប្រសិនបើមានរូបភាពនៅទំព័រដំបូង គួរឱ្យចាប់អារម្មណ៍ និងផ្តល់ព័ត៌មានច្រើនអំពីរឿង គ្រូនិយាយ និងសួរ៖ "**មើលរូបនេះ...។ តើប្អូនឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ? តើ...(តួអង្គ)កំពុងធ្វើអ្វី?**"

4. <u>ណែនាំពីសៀវភៅ</u>

គ្រូនិយាយ៖ "**ឥឡូវអ្នកទាំងអស់គ្នាសូមមើលមកសៀវភៅដែលខ្ញុំនឹងអាន។**"

1. **ចំណងជើងនៃរឿងនេះ គឺ**…………………..។
2. **អ្នកនិពន្ធឈ្មោះ** ……………………..។
3. **អ្នកគូររូប គឺ**……………………….។

5. ណែនាំពាក្យថ្មី១ទៅ៣ពាក្យ

គ្រូនិយាយ៖ "**មុនពេលខ្ញុំអានរឿង, ខ្ញុំចង់ណែនាំពាក្យថ្មី**......... ។"

ពន្យល់ពាក្យថ្មីដល់សិស្សដោយប្រើរូបភាពនៅក្នុងសៀវភៅ វត្ថុ ឬសកម្មភាព។ ឧទាហរណ៍៖ចង្អុលរូបនៅក្នុងសៀវភៅ ឬបង្ហាញវត្ថុ។ **នេះគឺ....**។

ធ្វើសកម្មភាពដើម្បីបង្ហាញន័យពាក្យ។ **នេះគឺ.....**។

ប្រសិនបើពាក្យនោះមិនអាចណែនាំដោយប្រើរូបភាព វត្ថុ ឬសកម្មភាព ថាពាក្យនោះហើយពន្យល់ន័យពាក្យនោះដោយពាក្យផ្ទាល់ខ្លួន។

ធ្វើដូចខាងលើនេះសារឡើងវិញ ចំពោះពាក្យទី២ និង/ឬទី៣សម្រាប់ពាក្យបន្ទាប់។

ខ-៣) ពេលអាន ១០-១៥ នាទី | ក្រុមធំ

**ឥឡូវខ្ញុំអានរឿងនេះ សម្រាប់អ្នកទាំងអស់គ្នា។**

1. អានរឿងយឺតៗ និងច្បាស់ៗដោយមានការលើកដាក់សំឡេង និងកាយវិការ

ប្រើខ្សែភ្នែកសម្លឹងទៅសិស្សក្នុងពេលអ្នកអាន។ ផ្លាស់ប្តូរសំឡេងរបស់អ្នកតាមតួអង្គផ្សេងៗនៅក្នុងរឿង។ ផ្លាស់ប្តូរការបង្ហាញទឹកមុខ ដើម្បីបង្ហាញពីអារម្មណ៍តាមសាច់រឿង។

**ពេលអានរឿង គ្រូត្រូវអង្គុយ។**

2. បង្ហាញរូបភាពសំខាន់ៗពីក្នុងរឿង

ក្នុងពេលអាន គ្រូត្រូវឈប់ត្រង់រូបភាពសំខាន់មួយចំនួនដែលបានត្រៀមរួចស្រាប់ ហើយបង្ហាញទៅសិស្ស។ ការបង្ហាញរូបភាពទាំងនេះ អាចជួយសិស្សឱ្យយល់ពីខ្លឹមសាររឿងបាន។ គ្រូត្រូវប្រាកដថាសិស្សទាំងអស់អាចមើលឃើញរូបភាព។ សូមជៀសវាងដាច់ខាត "**ពន្យល់រូបភាព ឬអត្ថបទទៅឱ្យសិស្ស**"។

3. សួរសំណួរទស្សន៍ទាយ ២ ទៅ ៣សំណួរ

ពេលអានទៅដល់កន្លែង/ទំព័រសៀវភៅដែលអ្នកបានកំណត់ចំណាំទុកសម្រាប់សួរ សូមគ្រូឈប់ហើយសួរសំណួរទស្សន៍ទាយ៖ "**តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ទៅទៀត? ហេតុអ្វីបានជាអ្នកគិតថានឹងមានរឿងនោះកើតឡើងបន្ទាប់ទៀត?**"

គ្រូក៏អាចសួរបណ្តើរ បង្ហាញទំព័រសៀវភៅបណ្តើរ ដោយខ្សែភ្នែកលើកទឹកចិត្តសិស្សឱ្យចូលរួមឆ្លើយ។

**ចំណាំ៖** សូមលើកទឹកចិត្តសិស្សឱ្យចូលរួមឆ្លើយដោយសេរី ដោយមិនចាំបាច់ឱ្យក្រោកឈរឆ្លើយ ឬចង្អុលហៅសិស្សណាម្នាក់ឡើងឆ្លើយឡើយ។ គ្រូត្រូវបង្ហាញឥរិយាបថ ឬកាយវិការទទួលយកចម្លើយពីសិស្សទាំងអស់ ដោយមិនមានការវិនិច្ឆ័យថាជាចម្លើយត្រូវ ឬខុសឡើយ។

## ខ-៤) ក្រោយពេលអាន ៤-៧ នាទី | ក្រុមធំ

1. <u>សួរ១ទៅ២សំណួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង</u>

   **ឥឡូវយើងនឹងជជែកគ្នាអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង។** ឧទាហរណ៍៖
   - **តើមានអ្វីកើតឡើងលើ**.........(**តួអង្គសំខាន់**)?
   - **តើ**......(**តួអង្គ**) **មានអារម្មណ៍យ៉ាងណា នៅពេលដែល**.........(**អ្វីដែលបានកើតឡើង**)?

2. <u>ណែនាំសិស្ស ដើម្បីរំឭកពីផ្នែកសំខាន់ៗនៃរឿង</u>

   បង្ហាញទំព័រ/រូបភាពម្តងមួយទំព័រៗ ពី ៣ទៅ៥កន្លែងសំខាន់ៗនៃរឿង រួចសួរសំណួរ៖
   - សម្រាប់រូបភាពទី១៖ **តើមានអ្វីបានកើតឡើងដំបូង នៅក្នុងរឿងនេះ?** ប្រសិនបើសិស្សឆ្លើយត្រូវ បន្តទៅសំណួរមួយទៀត។ ប្រសិនបើសិស្សឆ្លើយមិនត្រូវ, និយាយ៖ **មិនអីទេ, តើនរណាអាចនឹកឃើញអ្វីដែលបានកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ។
   - បង្ហាញរូបភាពនៃផ្នែកបន្ទាប់រួចសួរ៖ **តើមានអ្វីកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ១ទៅ២នាក់។ ប្រសិនបើសិស្សឆ្លើយមិនត្រូវ កុំនិយាយថា "ខុស"។ គ្រូសួរទៅសិស្សផ្សេង។
   - បង្ហាញផ្នែកបន្ទាប់ទៀតនៃរឿងរួចសួរ៖ **តើមានអ្វីកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ៣ទៅ៤។ សួរសំណួរឡើងវិញ ហើយទទួលចម្លើយ រហូតដល់រូបភាពចុងបញ្ចប់នៃរឿង។
   - បង្ហាញផ្នែកចុងក្រោយនៃរឿង។ **តើមានអ្វីកើតឡើងនៅចុងបញ្ចប់នៃរឿង?** ទទួលចម្លើយ **ល្អណាស់! យើងបានមើលឃើញពីផ្នែកសំខាន់ៗនៃរឿងនេះ!**

3. <u>សួរសំណួរ «ហេតុអ្វី» ១ទៅ២សំណួរ</u>

   ជាឧទាហរណ៍៖ **ហេតុអ្វីបានជា** (តួអង្គ)..........(ធ្វើសកម្មភាព)?

4. <u>ឱ្យកុមារស្ម័គ្រចិត្តធ្វើត្រាប់តាមកាយវិការខ្លះ និងធ្វើត្រាប់តាមសំឡេងខ្លះៗក្នុងរឿង</u>

   បើកទៅទំព័រណាមួយដែលមានសកម្មភាពល្អរបស់តួអង្គ។ ធ្វើកាយវិការតាមសកម្មភាពនោះ ហើយឱ្យកុមារធ្វើតាម។ ជ្រើសរើសសិស្សម្នាក់ស្ម័គ្រចិត្តធ្វើត្រាប់សកម្មភាព និងសំឡេងដូចតួអង្គ។

*<u>ប្រសិនបើសល់ពេលឱ្យកុមារ៖</u>*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬខ្ទីសៀវភៅ*

## III. អំណានចូលរួម

### ១) និយមន័យ

អំណានចូលរួម គឺជាសកម្មភាពដែលគ្រូប្រចាំថ្នាក់ជ្រើសរើសសៀវភៅរឿងមួយដែលមានទំហំធំសម្រាប់សិស្សអាចមើលឃើញនិងអានអក្សរបាន មានកម្រិតអានស្មើ ឬទាបជាងសមត្ថភាពសិស្សរបស់ខ្លួន និងផ្តល់គំរូនៃរបៀបអានទៅកាន់សិស្ស ដោយលើកដាក់សំឡេង មានកាយវិការទាក់ទាញតាមខ្លឹមសាររឿងខ្លះៗ ប្រកបដោយភាពរីករាយ និងលើកទឹកចិត្តសិស្ស។ អំណានចូលរួម ត្រូវអនុវត្តអំណានចំនួន២ដង ដោយលើកទឹកចិត្ត និងផ្តល់ឱកាសដល់សិស្សចូលរួមអានជាមួយនៅផ្នែកខ្លះនៃអត្ថបទ ឬខ្លឹមសាររឿង។ សកម្មភាពអំណាននេះ ត្រូវបានលើកទឹកចិត្តឱ្យធ្វើញឹកញាប់ជាមួយក្រុមសិស្សថ្នាក់ទី១-៣ ច្រើនជាងក្រុមសិស្សថ្នាក់ទី៤-៦។

### ២) គោលបំណង

- លើកទឹកចិត្ត និងធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការអាន
- ផ្តល់ជាគំរូល្អនៃរបៀបអាន
- ណែនាំប្រភេទផ្សេងៗគ្នានៃរឿងដល់សិស្ស
- លើកទឹកចិត្តសិស្សឱ្យអាន នៅក្នុងបរិយាកាសនៃការជួយគាំទ្រ
- លើកកម្ពស់ទម្លាប់នៃការអាន។

### ៣) ដំណើរការសកម្មភាពអំណានចូលរួម

#### ក) លំនាំគោលនៃការធ្វើសកម្មភាពអំណានចូលរួម

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅត្រូវតាមកម្រិត ឬទាបជាងកម្រិតអានរបស់កុមារ |

#### ក-១) ដំណាក់កាលត្រៀម មុនពេលធ្វើសកម្មភាពអំណាន

៥-៧ នាទី | ក្រុមធំ

ការស្វាគមន៍ដល់សិស្សដែលបានមកបណ្ណាល័យ។

1. ឱ្យកុមារដើរមើល និងអានសម្ភារព្រីនរីច
2. គ្រូជ្រើសរើសសៀវភៅ១ក្បាល ហើយអាន១ចប់
3. កំណត់ពីកន្លែងដែលត្រូវសួរសំណួរទស្សន៍ទាយ២ទៅ៣សំណួរ
4. កំណត់ពាក្យថ្មី១ទៅ៣ពាក្យ ដើម្បីណែនាំ
5. រំឭកដល់សិស្សពីគោលការណ៍បណ្ណាល័យ និងកម្រិតសៀវភៅ។

#### ក-២) មុនពេលអានលើកទី១

៣-៥ នាទី | ក្រុមធំ

1. បង្ហាញក្របសៀវភៅ។

2a. សួរសំណួរអំពីរូបភាពនៅលើក្រប។

- **តើអ្នកទាំងអស់គ្នាឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ?**
- **តើអ្នកឃើញមាន.......ប៉ុន្មាន?**
- **តើពួកគេកំពុងធ្វើអ្វី?**
- **តើអ្នកគិតថា នរណាខ្លះជាតួអង្គនៅក្នុងរឿងនេះ?**

2b. សួរសំណួរផ្សារភ្ជាប់រូបភាពទៅនឹងជីវភាពរស់នៅរបស់កុមារ។

- **តើអ្នកធ្លាប់ឃើញ.................ដែរឬទេ?**
- **តើនៅផ្ទះអ្នកមាន....................ដែរឬទេ?**
- **តើ......ធ្លាប់មានអ្វីកើតឡើងដល់អ្នកទេ?**

2c. សួរសំណួរទស្សន៍ទាយ ១ទៅ២សំណួរ

- **តើអ្នកគិតថានឹងមានអ្វីកើតឡើងនៅក្នុងរឿងនេះ?**
- **តើអ្នកគិតថាតួអង្គទាំងនេះនឹងធ្វើអ្វី?**

3. សួរ១ទៅ២សំណួរអំពីរូបភាពនៅលើទំព័រដំបូង (ប្រសិនបើរូបភាពគួរឱ្យចាប់អារម្មណ៍)
4. ណែនាំអំពីសៀវភៅ (អានចំណងជើង ឈ្មោះអ្នកនិពន្ធ ឈ្មោះអ្នកគូរគំនូរ)
5. ណែនាំពាក្យថ្មី១ទៅ៣ពាក្យ

## ក-៣) ពេលអានលើកទី១

៧-១០ នាទី | ក្រុមធំ

1. គ្រូ កាន់/រៀបចំសៀវភៅ និងធានាថា សិស្សទាំងអស់អាចមើលឃើញរូបភាព និងអត្ថបទគ្រប់ទំព័រ។
2. អានរឿងយឺតៗ និងច្បាស់ៗ ដោយលើកដាក់សំឡេង និងកាយវិការតាមខ្លឹមសាររឿង។
3. សួរសំណួរទស្សន៍ទាយ២ទៅ៣សំណួរ៖ **តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ទៅទៀត?**

## ក-៤) ក្រោយពេលអានលើកទី១

៤-៧ នាទី | ក្រុមធំ

1. សួរសំណួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង៖ **នរណា? អ្វី? កន្លែងណា? ពេលណា?**
2. រំឭកឡើងវិញអំពីផ្នែកសំខាន់ៗនៃរឿង៖ **តើមានអ្វីបានកើតឡើងដំបូងនៅក្នុងរឿងនេះ? តើមានអ្វីកើតឡើងបន្ទាប់ទៀត? តើមានអ្វីកើតឡើងនៅចុងបញ្ចប់?**
3. សួរសំណួរ«ហេតុអ្វី» ងាយៗ ១ទៅ២សំណួរ៖ **ហេតុអ្វីបាន (តួអង្គ)..........(ធ្វើសកម្មភាព)?**

## ក-៥) ពេលអានលើកទី២

៧-១០ នាទី | ក្រុមធំ

1. គ្រូឱ្យសិស្សអានជាមួយ និងចូលរួមក្នុងការអាន។

2. គ្រូអានរឿងដោយលើកដាក់សំឡេង និងកាយវិការ ដោយមានឧបករណ៍ចង្អុល ឬចង្អុលដៃអូសពីក្រោមពាក្យ/ឃ្លា/ល្បះទាំងនោះ។
3. គ្រូស្នើសុំឱ្យសិស្សអានពាក្យ/ឃ្លា/ល្បះណា ដែលគួរឱ្យចាប់អារម្មណ៍ម្តងទៀតជាមួយ។
4. ឱ្យកុមារចូលរួមធ្វើកាយវិការ ឬសំឡេងជាមួយអ្នក។

*ប្រសិនបើសល់ពេលឱ្យកុមារបន្តធ្វើសកម្មភាពៈ*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬ ខ្ទីសៀវភៅ*

## ខ) លំនាំលម្អិតនៃការធ្វើសកម្មភាពអំណានចូលរួម

### ខ-១) ដំណាក់កាលត្រៀម មុនពេលធ្វើអំណាន

៥-៧ នាទី | ក្រុមធំ

1. <u>កិច្ចស្វាគមន៍ និងការណែនាំ</u>
   នៅពេលដែលសិស្សចូលដល់បណ្ណាល័យ គ្រូបង្រៀនត្រូវណែនាំពួកគេឱ្យអង្គុយលើឥដ្ឋពីមុខអ្នក។ គ្រូអង្គុយលើកៅអី និងនិយាយទៅកាន់សិស្សៈ

   ***" សូមស្វាគមន៍អ្នកទាំងអស់គ្នាដែលបានមកបណ្ណាល័យ។ មុនចាប់ផ្តើមស្តាប់គ្រូអានរឿង អ្នកទាំងអស់ក្រោកឈរ ហើយដើរអានសម្ភារព្រីនរីចដែលតាំងនៅក្នុងបណ្ណាល័យ និងសូមត្រឡប់មកអង្គុយ ទីនេះវិញ នៅពេលគ្រូហៅ។ "***

2. <u>គ្រូជ្រើសរើសសៀវភៅ១ក្បាល ហើយអាន</u>
   ពេលសិស្សដើរអានព្រីនរីច គ្រូជ្រើសរើសសៀវភៅ១ក្បាល ហើយអានយ៉ាងហោចណាស់ឱ្យបានមួយចប់ មុនពេលអ្នកអានជាមួយសិស្ស ព្រោះអ្នកចាំបាច់ត្រូវយល់សាច់រឿងជាមុន។

   សៀវភៅដែលជ្រើសរើសមកអានក្នុងម៉ោងនេះ គួរតែជាប្រភេទសៀវភៅដែលខុសគ្នាជាមួយសៀវភៅដែលបានអានកាលពីម៉ោងបណ្ណាល័យលើកមុន (ឧ.រឿងផ្សងព្រេង រឿងអាថ៌កំបាំង ឬរឿងសប្បាយៗ)។ សិស្សគួរតែបានស្តាប់រឿងប្រភេទផ្សេងៗពីម៉ោងបណ្ណាល័យមួយទៅមួយទៀត។ គ្រូប្រចាំថ្នាក់ ត្រូវរៀបចំដើម្បី<u>**អានរឿង**</u> ជាជាង <u>**និទានរឿង**</u> តាមការចងចាំ។

3. <u>កំណត់ទំព័រ និងកន្លែងដែលត្រូវសួរសំណួរទស្សន៍ទាយ</u>
   កំណត់**២ - ៣ កន្លែង** នៅក្នុងសៀវភៅរឿង ដើម្បីសួរសំណួរទស្សន៍ទាយដោយដាក់ក្រដាស់ពណ៌ ឬសញ្ញាសំគាល់ត្រង់កន្លែងដែលត្រូវសួរ។ សំណួរទាំងនេះគួរតែនៅក្នុងរឿងត្រង់កន្លែងដែលនឹងមានអ្វីកើតឡើងបន្ទាប់ទៀតដែលមិនច្បាស់លាស់។

4. <u>កំណត់ពាក្យថ្មីដើម្បីណែនាំ</u>

ជ្រើសរើសពាក្យថ្មី ១ - ៣ ពាក្យពីក្នុងរឿង ដើម្បីណែនាំដល់សិស្ស។ ប្រសិនបើអាចធ្វើបាន ការណែនាំពាក្យថ្មីនេះត្រូវប្រើរូបភាពក្នុងសៀវភៅ វត្ថុ ឬសកម្មភាព។ ត្រូវត្រៀមរៀបចំពន្យល់ន័យរបស់ពាក្យប្រសិនបើអ្នកមិនអាចប្រើប្រាស់រូបភាព វត្ថុ ឬសកម្មភាពណាមួយបាន។

សូមចងចាំថា ពាក្យដែលជ្រើសរើសគួរតែជាពាក្យថ្មី ដែលយើងគិត/សន្មត់ថា សិស្សមិនដែលធ្លាប់ដឹង។ ពាក្យទាំងនេះអាចជាពាក្យ ឬគំនិតដែលសិស្សមិនធ្លាប់ស្គាល់។ ឧទាហរណ៍ខ្លះៗនៃពាក្យថ្មីទាំងនោះដូចជា «ប្រឡំ» ឬ «ក្បួន» ដែលសិស្សមិនដឹងពីអត្ថន័យនៃពាក្យទាំងនេះ។ ពាក្យដូចជា «ទឹក» និង «គោ» គឺមិនគួរជ្រើសរើសទេ ព្រោះសិស្សភាគច្រើនបានស្គាល់ពាក្យ និងន័យរួចហើយ។

ប្រសិនបើមានពាក្យពិបាកនៅក្នុងសៀវភៅដែលសិស្សមិនដឹងច្រើនជាង៣ពាក្យ សូមជ្រើសរើសយកតែ ៣ពាក្យ ដែលសំខាន់ជាងគេបំផុត និងអាចជួយសិស្សឱ្យយល់ពីខ្លឹមសាររឿង។

## <u>ដំណាក់កាលចាប់ផ្តើមធ្វើសកម្មភាពអំណានចូលរួមជាមួយសិស្ស</u>

<u>ហៅសិស្សមកជួបជុំគ្នាវិញ</u>

DO

គ្រូអង្គុយនៅលើកៅអី និងហៅសិស្សមកកន្លែងដើមវិញ។ សិស្សអង្គុយតាមសម្រួលជារាងស្នែងក្របី ជាជាងអង្គុយជាជួរ។ ឱ្យសិស្សអង្គុយជិតៗអ្នកតាមដែលអាចធ្វើបាន។ រំឭកពួកគេអំពីគោលការណ៍បណ្ណាល័យ (ពុំចាំបាច់ធ្វើរាល់ម៉ោងបណ្ណាល័យទេ)។ ប្រាប់សិស្សពីការចាប់ផ្តើមសកម្មភាពអំណាននេះ។ "**ថ្ងៃនេះយើងនឹងធ្វើសកម្មភាពអំណានចូលរួម**"។

### ខ-២) មុនពេលអានលើកទី១

៣-៥ នាទី | ក្រុមធំ

1. <u>បង្ហាញក្របសៀវភៅ</u>

ជាជម្រើស៖ បង្ហាញក្របសៀវភៅតែម្តង ឬយកក្រដាសបាំងចំណងជើងហើយបើកឃើតៗ។

គ្រូនិយាយ៖ "**ខ្ញុំចង់អានរឿងមួយឱ្យអ្នកទាំងអស់គ្នាស្តាប់**"។

2a. <u>សួរសំណួរអំពីរូបភាពនៅលើក្របសៀវភៅ</u>

គ្រូនិយាយ និងសួរ៖ "**មើលរូបភាពនៅលើក្របមុខនៃសៀវភៅនេះ។ តើអ្នកទាំងអស់គ្នាឃើញអ្វីខ្លះ? តើមាន.....ប៉ុន្មាន? តើអ្នកគិតថា............កំពុងធ្វើអ្វី?**"

ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗខាងលើ។ គ្រូបន្តសួរ៖ "**តើអ្នកគិតថានរណាជាតួអង្គសំខាន់នៃរឿងនេះ?**" ទទួលចម្លើយ២ទៅ៣នាក់។

(សម្រាប់សិស្សថ្នាក់ទី១ អំឡុងពេល២ទៅ៣ម៉ោងបណ្ណាល័យដំបូង អ្នកអាចប្រាប់សិស្សតែម្តង ប្រសិនបើសង្កេតឃើញថា សិស្សលំបាកចូលរួមជាមួយសំណួរទាំងនេះ)។

2b. <u>សួរសំណួរផ្សារភ្ជាប់រូបភាពទៅនឹងជីវភាពរស់នៅរបស់កុមារ</u>

គ្រូសួរ៖ "**តើអ្នកធ្លាប់ឃើញ………? តើនៅផ្ទះប្អូនមាន……….ដែរឬទេ?**"
ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗ។

2c. <u>សួរសំណួរទស្សន៍ទាយខ្លឹមសាររឿង ២ទៅ៣ សំណួរ</u>
គ្រូសួរ៖ "**តើអ្នកគិតថានឹងមានអ្វីកើតឡើងនៅក្នុងរឿងនេះ? តើអ្នកគិតថាតួអង្គ…នេះនឹងធ្វើអ្វី?**"
ទទួលចម្លើយ២ទៅ៣នាក់សម្រាប់សំណួរនីមួយៗ។

3. <u>សួរ១ទៅ២សំណួរអំពីរូបភាពនៅទំព័រដំបូង</u>
ប្រសិនបើមានរូបភាពនៅទំព័រដំបូង គួរឱ្យចាប់អារម្មណ៍ និងផ្តល់ព័ត៌មានច្រើនអំពីរឿង គ្រូនិយាយ និងសួរ៖ "**មើលរូបនេះ…។ តើប្អូនឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ? តើ…(តួអង្គ)កំពុងធ្វើអ្វី?**"

4. <u>ណែនាំពីសៀវភៅ</u>
គ្រូនិយាយ៖ "**ឥឡូវអ្នកទាំងអស់គ្នាសូមមើលមកសៀវភៅដែលខ្ញុំនឹងអាន។**"
   1. **ចំណងជើងនៃរឿងនេះ គឺ**…………………..។
   2. **អ្នកនិពន្ធឈ្មោះ** ……………………..។
   3. **អ្នកគូររូប គឺ**……………………….។

5. <u>ណែនាំពាក្យថ្មី១ទៅ៣ពាក្យ</u>
គ្រូនិយាយ៖ "**មុនពេលខ្ញុំអានរឿង ខ្ញុំចង់ណែនាំពាក្យថ្មី……….** ។"
ពន្យល់ពាក្យថ្មីដល់សិស្សដោយប្រើរូបភាពនៅក្នុងសៀវភៅ វត្ថុ ឬសកម្មភាព។ ឧទាហរណ៍៖ចង្អុលរូបនៅក្នុងសៀវភៅ ឬបង្ហាញវត្ថុ។ **នេះគឺ….។**

ធ្វើសកម្មភាពដើម្បីបង្ហាញន័យរបស់ពាក្យ។ **នេះគឺ…..។**

ប្រសិនបើពាក្យនោះមិនអាចណែនាំដោយប្រើរូបភាព វត្ថុ ឬសកម្មភាព គ្រូថាពាក្យនោះហើយពន្យល់ន័យរបស់ពាក្យនោះដោយពាក្យផ្ទាល់ខ្លួន។

ធ្វើដូចខាងលើនេះសារឡើងវិញ ចំពោះពាក្យទី ២ និង/ឬទី៣សម្រាប់ពាក្យបន្ទាប់។

## ខ-៣) ពេលអានលើកទី១

១០-១៥ នាទី | ក្រុមធំ

### ឥឡូវខ្ញុំអានរឿងនេះ សម្រាប់អ្នកទាំងអស់គ្នា។

1. គ្រូ កាន់/រៀបចំសៀវភៅ និងធានាថា សិស្សទាំងអស់អាចមើលឃើញរូបភាព និងអត្ថបទគ្រប់ទំព័រ។
2. <u>អានរឿងយឺតៗ និងច្បាស់ៗដោយមានការលើកដាក់សំឡេង និងកាយវិការ</u>

ប្រើខ្សែភ្នែកសម្លឹងទៅសិស្សក្នុងពេលអ្នកអាន។ ផ្លាស់ប្តូរសំឡេងរបស់អ្នកតាមតួអង្គផ្សេងៗនៅក្នុងរឿង។ ផ្លាស់ប្តូរល្បឿននៃការអានតាមសកម្មភាពយឺត ឬលឿន។ ផ្លាស់ប្តូរការបង្ហាញទឹកមុខ ដើម្បីបង្ហាញពីអារម្មណ៍តាមសាច់រឿង។

**ពេលអានរឿង គ្រូត្រូវអង្គុយ។** គ្រូត្រូវប្រាកដថា សិស្សទាំងអស់អាចមើលឃើញរូបភាព និងអត្ថបទគ្រប់ទំព័រ ស្របគ្នាជាមួយគ្រូកំពុងអាន។ សូមចៀសវាងដាច់ខាត "**ពន្យល់រូបភាព ឬអត្ថបទទៅឱ្យសិស្ស**"។

3. <u>សួរសំណួរទស្សន៍ទាយ ២ ទៅ ៣សំណួរ</u>
   ពេលអានទៅដល់កន្លែង/ទំព័រសៀវភៅដែលអ្នកបានកំណត់ចំណាំទុកសម្រាប់សួរ សូមគ្រូឈប់ ហើយសួរសំណួរទស្សន៍ទាយ៖ "**តើអ្នកគិតថានឹងមានរឿងអ្វីកើតឡើងបន្ទាប់ទៅទៀត? ហេតុអ្វីបានជាអ្នកគិតថានឹងមានរឿងនោះកើតឡើងបន្ទាប់ទៀត?**"

   <u>**ចំណាំ**</u>**៖** សូមលើកទឹកចិត្តសិស្សចូលរួមឆ្លើយដោយសេរី ដោយមិនចាំបាច់ឱ្យសិស្សក្រោកឈរឆ្លើយ ឬចង្អុលហៅសិស្សណាម្នាក់ឡើងឆ្លើយឡើយ។ គ្រូត្រូវបង្ហាញឥរិយាបថ ឬកាយវិការទទួលយកចម្លើយពីសិស្សទាំងអស់ ដោយមិនមានការវិនិច្ឆ័យថាជាចម្លើយត្រូវ ឬខុសឡើយ។

## ខ-៤) ក្រោយពេលអាន លើកទី១ ៥-៧ នាទី | ក្រុមធំ

1. <u>សួរ១ទៅ២សំណួរអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង</u>
   **ឥឡូវយើងនឹងជជែកគ្នាអំពីអ្វីដែលបានកើតឡើងនៅក្នុងរឿង។** ឧទាហរណ៍៖
   - **តើមានអ្វីកើតឡើងលើ**.........(តួអង្គសំខាន់)**?**
   - **តើ**......(តួអង្គ) **មានអារម្មណ៍យ៉ាងណា នៅពេលដែល**.........(អ្វីដែលបានកើតឡើង)?

2. <u>ណែនាំសិស្ស ដើម្បីរំឭកឡើងវិញអំពីផ្នែកសំខាន់ៗនៃរឿង</u>
   បង្ហាញទំព័រ/រូបភាពម្តងមួយទំព័រៗ ពី ៣ទៅ៥កន្លែងសំខាន់ៗនៃរឿង រួចសួរសំណួរ៖
   - សម្រាប់រូបភាពទី១៖ **តើមានអ្វីបានកើតឡើងដំបូង នៅក្នុងរឿងនេះ?** ប្រសិនបើសិស្សឆ្លើយត្រូវ បន្តទៅសំណួរមួយទៀត។ ប្រសិនបើសិស្សឆ្លើយមិនត្រូវ គ្រូត្រូវនិយាយ៖ **មិនអីទេ តើនរណាអាចនឹកឃើញអ្វីដែលបានកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ។
   - បង្ហាញរូបភាពនៃផ្នែកបន្ទាប់រួចសួរ៖ **តើមានអ្វីកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ១ទៅ២នាក់។ ប្រសិនបើសិស្សឆ្លើយមិនត្រូវ កុំនិយាយថា "ខុស"។ គ្រូសួរទៅសិស្សផ្សេង។
   - បង្ហាញផ្នែកបន្ទាប់ទៀតនៃរឿងរួចសួរ៖ **តើមានអ្វីកើតឡើងបន្ទាប់ទៀត?** ទទួលចម្លើយ៣ទៅ៤។ សួរសំណួរឡើងវិញ ហើយទទួលចម្លើយ រហូតដល់រូបភាពចុងបញ្ចប់នៃរឿង។
   - បង្ហាញផ្នែកចុងក្រោយនៃរឿង។ **តើមានអ្វីកើតឡើងនៅចុងបញ្ចប់នៃរឿង?** ទទួលចម្លើយ **ល្អណាស់! យើងបានមើលឃើញពីផ្នែកសំខាន់ៗនៃរឿងនេះ!**

3. <u>សួរសំណួរ «ហេតុអ្វី» ងាយៗ ១ទៅ២សំណួរ</u>
   ជាឧទាហរណ៍៖ **ហេតុអ្វីបានជា** (តួអង្គ)..........(ធ្វើសកម្មភាព)?

## ខ-៥) ពេលអានលើកទី២ ៧-១០ នាទី | ក្រុមធំ

1. <u>គ្រូឱ្យសិស្សអានជាមួយ និងចូលរួមក្នុងការអាន</u>
   ឥឡូវយើងអានរឿងនេះម្តងទៀត។ ខ្ញុំនឹងអានរឿងនេះ ហើយអ្នកទាំងអស់គ្នាអាចអាន<u>**ជាមួយ**</u>ខ្ញុំបាន។
2. គ្រូអានរឿងលើកទី២ លើកដាក់សំឡេង និងកាយវិការ ដោយមានឧបករណ៍ចង្អុល ឬចង្អុលដៃអូសពីក្រោមពាក្យ/ឃ្លា/ល្បះទាំងនោះ។ សូមចំណាំថា ក្នុងពេលអានលើកទី២នេះ គ្រូត្រូវលើកទឹកចិត្តឱ្យសិស្ស<u>**អានជាមួយ**</u>អ្នក មិនមែនឱ្យសិស្ស<u>**អានតាម**</u>អ្នកទេ។
3. គ្រូស្នើសុំឱ្យសិស្សអានពាក្យ/ឃ្លា/ល្បះណា ដែលគួរឱ្យចាប់អារម្មណ៍ម្តងទៀតជាមួយ។ សូមឈប់អានបន្ត ត្រង់ពាក្យ/ឃ្លា ឬល្បះដែលគួរឱ្យចាប់អារម្មណ៍ ដើម្បីលើកទឹកចិត្តឱ្យសិស្សចូលរួមអាន។ គ្រូឈប់ និងនិយាយ៖ "**ឥឡូវយើងអានម្តងទៀតទាំងអស់គ្នា**"។ គ្រូសិស្ស អានពាក្យ/ឃ្លា ឬល្បះនោះម្តងទៀតព្រមគ្នា។
4. ឱ្យកុមារចូលរួមធ្វើកាយវិការ ឬសំឡេងជាមួយអ្នក។ គ្រូត្រូវឈប់អានបន្តិច បន្ទាប់ពីសំឡេង ឬសកម្មភាពគួរឱ្យចាប់អារម្មណ៍ ហើយនិយាយ៖ "**យើងធ្វើសំឡេងនេះទាំងអស់គ្នា**"។ គ្រូសិស្សធ្វើសំឡេងនោះព្រមជាមួយគ្នា។ គ្រូជ្រើសរើសសិស្សស្ម័គ្រចិត្តម្នាក់ ឱ្យធ្វើបង្ហាញដល់អ្នកដទៃទៀត ប្រសិនបើមាន។
5. អរគុណដល់សិស្សដែលបានចូលរួមអានជាមួយ។

<u>*ប្រសិនបើសល់ពេលឱ្យកុមារ៖*</u>

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬខ្ញីសៀវភៅ*

# IV. អំណានដៃគូ

## ១) និយមន័យ

អំណានដៃគូ គឺជាសកម្មភាពដែលសិស្សចាប់ដៃគូអានដោយស្ម័គ្រចិត្ត និងជ្រើសរើសសៀវភៅដែលសមស្របជាមួយសមត្ថភាពអាន និងជាទីពេញចិត្តរបស់ពួកគេ ក្រោមការដឹកនាំរបស់គ្រូប្រចាំថ្នាក់នៅក្នុងម៉ោងបណ្ណាល័យ។ សកម្មភាពអំណាននេះ ត្រូវបានលើកទឹកចិត្តឱ្យធ្វើញឹកញាប់ជាមួយក្រុមសិស្សថ្នាក់ទី ៤-៦ ច្រើនជាងក្រុមសិស្សថ្នាក់ទី១-៣។

## ២) គោលបំណង

- លើកទឹកចិត្ត និងធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការអាន
- លើកកម្ពស់ការចូលរួម ទំនាក់ទំនងល្អប្រសើរ និងការអានដោយម្ចាស់ការរបស់កុមារ
- ផ្តល់ឱកាសដល់សិស្ស បានអានសៀវភៅតាមជម្រើសរបស់ពួកគេ
- លើកទឹកចិត្តសិស្សឱ្យអាន នៅក្នុងបរិយាកាសនៃការជួយគាំទ្រពីដៃគូរបស់ពួកគេ
- លើកកម្ពស់ទម្លាប់នៃការអាន។

## ៣) ដំណើរការសកម្មភាពអំណានដៃគូ

### ក) លំនាំគោលនៃការធ្វើសកម្មភាពអំណានដៃគូ

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅតាមកម្រិតអានរបស់កុមារ |

**ក-១ កិច្ចស្វាគមន៍ និងការណែនាំ** ២-៣ នាទី | ក្រុមធំ

- ធ្វើការស្វាគមន៍ដល់សិស្ស ដែលបានមកបណ្ណាល័យ
- រំឭកសិស្សអំពីគោលការណ៍បណ្ណាល័យ
- ណែនាំប្រាប់សិស្ស អំពីសកម្មភាពអំណានដែលត្រូវធ្វើក្នុងថ្ងៃនេះ

**ក-២ មុនពេលអាន** ៣-៥ នាទី | ក្រុមធំ

1. ឱ្យសិស្សរកដៃគូ ហើយអង្គុយជាមួយគ្នា។
2. ឱ្យសិស្សចង្អុល និងប្រាប់ឈ្មោះកម្រិតសៀវភៅឱ្យបាន ៣កម្រិត នៅលើធ្នើរ ដែលពួកគេអាចនឹងចាប់ផ្តើមទៅជ្រើសរើស។
3. រំឭកដល់សិស្ស ឱ្យសួរគ្រូនៅពេលពួកគេត្រូវការឱ្យជួយ។
4. ឱ្យដៃគូទៅជ្រើសរើសសៀវភៅតាមលំដាប់លំដោយ។

**ក-៣ ពេលអាន** ១៥-២០ នាទី | ដៃគូ

1. សិស្សចាប់ផ្ដើមអង្គុយទន្ទឹមគ្នា ហើយអានដំណាលគ្នា។
2. គ្រូដើរសម្របសម្រួល និងពិនិត្យមើលថា ដៃគូពិតជាកំពុងអានជាមួយគ្នា។
3. គ្រូស្ដាប់កុមារអាន និងសរសើរដល់ការខំប្រឹងប្រែងរបស់កុមារ។
4. គ្រូប្រើតេស្តម្រាមដៃ៥ ដើម្បីពិនិត្យកម្រិតអានរបស់សិស្ស ប្រសិនបើមានដៃគូណាមួយមានបញ្ហា។
5. គ្រូពិនិត្យមើលរបៀបដែលកុមារកំពុងបើកសន្លឹកសៀវភៅ ហើយជួយពួកគេឱ្យបើកសន្លឹកឱ្យបានត្រឹមត្រូវ ប្រសិនបើចាំបាច់។

## ក-៤ ក្រោយពេលអាន

៥-៧ នាទី | ក្រុមធំ

1. ឱ្យសិស្សកាន់សៀវភៅរបស់ពួកគេ ហើយប្រមូលផ្ដុំមកអង្គុយយ៉ាងស្ងៀមស្ងាត់នៅកន្លែងដើម។
2. ឱ្យសិស្ស ៣ទៅ៤ដៃគូ ចែករំលែករឿងរ៉ាវអំពីសៀវភៅរបស់ពួកគេ។

   សម្រាប់ដៃគូនីមួយៗ សួរ១ទៅ២សំណួរ ក្នុងចំណោមសំណួរដូចខាងក្រោម៖
   - តើអ្នកចូលចិត្តរឿងដែលអ្នកអានឬទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
   - តើតួអង្គណាមួយ នៅក្នុងរឿង ដែលអ្នកចូលចិត្ត? ហេតុអ្វី?
   - តើរឿងនេះកើតឡើងនៅឯណា?
   - តើអ្នកចាប់អារម្មណ៍ចំណុចណាមួយជាងគេដែលបានកើតឡើងក្នុងរឿង?
   - តើផ្នែកណាដែលអ្នកពេញចិត្តនៅក្នុងរឿងនេះ? ហេតុអ្វី?
   - ប្រសិនបើអ្នកជា...(តួអង្គ)... តើអ្នកគួរធ្វើអ្វីខុសពីនេះទេ?
   - តើអ្វីដែលគួរឱ្យអស់សំណើចនៅក្នុងរឿងនេះ? ភ័យខ្លាច? សប្បាយរីករាយ? ទុក្ខព្រួយ?
   - តើអ្នកចង់ណែនាំរឿងនេះទៅមិត្តរួមថ្នាក់ដែរ ឬទេ? តើអ្នកគិតថាសិស្សផ្សេងទៀតចូលចិត្តអានវាទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
   - តើអ្នកគិតថា ហេតុអ្វីបានជាអ្នកនិពន្ធសរសេររឿងនេះ?

   អរគុណដល់សិស្សសម្រាប់ការចែករំលែក អំពីសៀវភៅរបស់អ្នក។

3. ឱ្យកុមារយកសៀវភៅទៅទុកនៅលើធ្នើរវិញ

*ប្រសិនបើសល់ពេលឱ្យកុមារ៖*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬខ្ទីសៀវភៅ*

## ខ) លំនាំលម្អិតនៃការធ្វើសកម្មភាពអំណានដៃគូ

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅតាមកម្រិតអានរបស់កុមារ |

### ខ-១ កិច្ចស្វាគមន៍ និងការណែនាំ

២-៣ នាទី | ក្រុមធំ

អង្គុយនៅលើកៅអី ហើយសិស្សអង្គុយលើឥដ្ឋនៅជិតអ្នកជាពាក់កណ្ដាលរង្វង់។

ធ្វើការស្វាគមន៍ដល់សិស្សដែលបានមកបណ្ណាល័យ។ រំឭកពួកគេពីគោលការណ៍បណ្ណាល័យ តាមម៉ោងនីមួយៗ រហូតដល់សិស្សស្គាល់ច្បាស់អំពីគោលការណ៍។

ផ្ដល់ព័ត៌មានដល់សិស្ស អំពីសកម្មភាពអំណានដៃគូត្រូវធ្វើ។

**ថ្ងៃនេះយើងនឹងធ្វើសកម្មភាពអំណានដៃគូ។**

### ខ-២ មុនពេលអាន

៣-៥ នាទី | ក្រុមធំ

SAY **ថ្ងៃនេះអ្នកនឹងមានពេលអានជាមួយមិត្តភក្តិ។ អ្នកនឹងអាចទៅរើសយកសៀវភៅដែលអ្នកចូលចិត្ត ហើយបន្ទាប់មកអ្នកអាចអានវាជាមួយគ្នា។**

1. ឱ្យសិស្សរកដៃគូ ហើយអង្គុយជាមួយគ្នា។

   ***អ្នកអាចជ្រើសរើសនរណាម្នាក់ ដែលអ្នកចូលចិត្តអានជាមួយ។ អ្នកនោះអាចជាមិត្តភក្តិ ឬអ្នកដែលអង្គុយជិតអ្នក ឬនរណាម្នាក់ដែលអ្នកចង់ចំណាយពេលអានជាមួយ។ ឥឡូវនេះចាប់ផ្ដើមរកមិត្តភក្តិ ហើយអង្គុយជាមួយគ្នា។***

   ឱ្យសិស្ស១ទៅ២នាទីចាប់ដៃគូ។ អាចឱ្យសិស្សចូល៣នាក់ក្នុង១ក្រុម ប្រសិនបើគ្មានគូ។

2. ឱ្យសិស្សចង្អុល និងប្រាប់ឈ្មោះកម្រិតសៀវភៅឱ្យបាន ៣កម្រិត នៅលើធ្នើរ ដែលពួកគេអាចនឹងចាប់ផ្ដើមទៅជ្រើសរើស។

   **តើសៀវភៅ៣កម្រិតដែលកូនៗគួរចាប់ផ្ដើមជ្រើសរើសយកមកអានមានអ្វីខ្លះ?**

   ឱ្យសិស្សប្រាប់កម្រិត និងចង្អុលទៅធ្នើរដែលមានសៀវភៅទាំង៣កម្រិតនោះ។

   **ចង្អុលទៅកម្រិត...។ ចង្អុលទៅកម្រិត...។ ចង្អុលទៅកម្រិត...។**

3. រំឭកដល់សិស្ស ឱ្យសួរគ្រូនៅពេលពួកគេត្រូវការឱ្យជួយ។

   **ខ្ញុំនឹងដើរមើលអំឡុងពេលកូនៗអាន។ បើសិនបើជួបពាក្យពិបាកមិនចេះអាន កូនអាចមកសួរខ្ញុំ។**

4. ឱ្យដៃគូទៅជ្រើសរើសសៀវភៅតាមលំដាប់លំដោយ។

   **សុំដៃគូនីមួយៗ រើសសៀវភៅដែលអ្នកចូលចិត្ត។ បន្ទាប់មករកកន្លែងអង្គុយអានជាមួយគ្នា។ យើងមានពេលអានជាមួយគ្នាពី១៥ ទៅ ២០នាទី។**

   ឱ្យសិស្ស៤ទៅ៥គូ ចេញទៅរកសៀវភៅដោយស្ងៀមស្ងាត់។ នៅពេលដៃគូវេនទី១ បានរើសសៀវភៅរួច ឱ្យសិស្ស៤ទៅ៥ដៃគូទៀត ទៅរើសសៀវភៅម្តង។ បន្តរហូតដល់ដៃគូទាំងអស់បានរើសសៀវភៅ។

   ប្រសិនបើដៃគូខ្លះ មានការលំបាកក្នុងការរើសសៀវភៅ អាចឱ្យដៃគូផ្សេងទៀតទៅរើសមុន ហើយចាប់ផ្តើមអាន។ បន្ទាប់មកគ្រូជួយដៃគូដែលជួបការលំបាកនោះ។ សួរថា សៀវភៅប្រភេទអ្វីដែលពួកគេចូលចិត្តអាន។ ជួយរកសៀវភៅនោះឱ្យពួកគេ។ ប្រសិនបើសិស្សនៅតែចំណាយពេលយូរក្នុងការរើស ហើយមិនដឹងសៀវភៅប្រភេទណាដែលត្រូវរើស គ្រូរើសសៀវភៅ១ក្បាលឱ្យពួកគេ ដែលអ្នកគិតថាពួកគេនឹងចូលចិត្ត។

## ខ-៣ ពេលអាន

១៥-២០ នាទី | ដៃគូ

1. សិស្សចាប់ផ្តើមអង្គុយទន្ទឹមគ្នា ហើយអានដំណាលគ្នា។
2. គ្រូដើរសម្របសម្រួល និងពិនិត្យមើលថា ដៃគូពិតជាកំពុងអានជាមួយគ្នា។ ពិនិត្យមើលថាសិស្សពិតជាអង្គុយទន្ទឹមគ្នា មិនមែនអង្គុយទល់មុខគ្នាទេ។
3. គ្រូស្តាប់កុមារអាន និងសរសើរដល់ការខំប្រឹងប្រែងរបស់កុមារ។ កុមារអានដំណាលគ្នាជាដៃគូ។
4. គ្រូប្រើតេស្តម្រាមដៃ៥ ដើម្បីពិនិត្យកម្រិតអានរបស់សិស្ស ប្រសិនបើមានដៃគូណាមានបញ្ហា។ ប្រសិនបើសិស្សមានការលំបាកក្នុងការអាន ឬរើសសៀវភៅ ពិនិត្យមើលកម្រិតអានរបស់ពួកគេ ហើយឱ្យពួកគេទៅរើសសៀវភៅដែលមានកម្រិតទាបជាង ឬខ្ពស់ជាង ប្រសិនចាំបាច់។
5. គ្រូពិនិត្យមើលរបៀបដែលកុមារកំពុងបើកសន្លឹកសៀវភៅ ហើយជួយពួកគេឱ្យបើកសន្លឹកឱ្យបានត្រឹមត្រូវ ប្រសិនបើចាំបាច់។

## ខ-៤ ក្រោយពេលអាន

៥-៧ នាទី | ក្រុមធំ

នៅពេលអស់ម៉ោង បញ្ចប់ការអានដៃគូ។

**ឥឡូវនេះ អស់ម៉ោងអានហើយ។ ប្រសិនបើអ្នកចូលចិត្ត ហើយចង់អានសៀវភៅរបស់អ្នកបន្ត អ្នកអាចខ្ចីវាទៅអាននៅផ្ទះ។**

1. ឱ្យសិស្សកាន់សៀវភៅរបស់ពួកគេ ហើយមកប្រមូលផ្តុំអង្គុយយ៉ាងស្ងៀមស្ងាត់នៅកន្លែងដើម។

   **ឥឡូវយកសៀវភៅដែលអ្នកបានអានរួចមក ហើយអង្គុយនៅទីនេះ។**

2. ឱ្យសិស្ស៣ទៅ៤ដៃគូ ចែករំលែករឿងរ៉ាវអំពីសៀវភៅរបស់ពួកគេ។

**តើដៃគូណាដែលចង់ចែករំលែករឿងរ៉ាវអំពីសៀវភៅ ដែលអ្នកបានអានជាមួយគ្នា?**

សម្រាប់ដៃគូនីមួយៗ សួរ១ទៅ២សំណួរ ក្នុងចំណោមសំណួរដូចខាងក្រោម៖

- តើអ្នកចូលចិត្តរឿងដែលអ្នកអានឬទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
- តើតួអង្គណាមួយ នៅក្នុងរឿង ដែលអ្នកចូលចិត្ត? ហេតុអ្វី?
- តើរឿងនេះកើតឡើងនៅឯណា?
- តើអ្នកចាប់អារម្មណ៍ចំណុចណាមួយជាងគេដែលបានកើតឡើងក្នុងរឿង?
- តើផ្នែកណាដែលអ្នកពេញចិត្តនៅក្នុងរឿងនេះ? ហេតុអ្វី?
- ប្រសិនបើអ្នកជា...(តួអង្គ)... តើអ្នកគួរធ្វើអ្វីខុសពីនេះទេ?
- តើអ្វីដែលគួរឱ្យអស់សំណើចនៅក្នុងរឿងនេះ? ភ័យខ្លាច? សប្បាយរីករាយ? ទុក្ខព្រួយ?
- តើអ្នកចង់ណែនាំរឿងនេះទៅមិត្តរួមថ្នាក់ដែរ ឬទេ? តើអ្នកគិតថាសិស្សផ្សេងទៀតចូលចិត្តអានវាទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
- តើអ្នកគិតថា ហេតុអ្វីបានជាអ្នកនិពន្ធសរសេររឿងនេះ?

អរគុណដល់សិស្សសម្រាប់ការចែករំលែក អំពីសៀវភៅរបស់អ្នក។

3. <u>ឱ្យកុមារយកសៀវភៅទៅទុកនៅលើធ្នើរវិញ</u>

**ឥឡូវនេះការធ្វើអំណានយើងចប់ហើយ សូមកូនៗយកសៀវភៅទៅទុកលើធ្នើរវិញ ហើយដាក់វានៅកន្លែងដើមវិញ។**

*<u>ប្រសិនបើសល់ពេលឱ្យកុមារ៖</u>*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- *អានសៀវភៅ ឬខ្ទីសៀវភៅ*

## V. អំណានបុគ្គល

### ១) និយមន័យ

អំណានបុគ្គល គឺជាសកម្មភាពដែលសិស្សម្នាក់ៗទទួលបានឱកាសអានសៀវភៅតាមជម្រើសដែលខ្លួនពេញចិត្ត ដើម្បីពង្រឹង និងបង្កើនការអានរបស់ខ្លួនប្រកបដោយភាពម្ចាស់ការ ក្រោមការដឹកនាំរបស់គ្រូប្រចាំថ្នាក់នៅក្នុងម៉ោងបណ្ណាល័យ។ សកម្មភាពអំណាននេះ ត្រូវបានលើកទឹកចិត្តឱ្យធ្វើញឹកញាប់ជាមួយក្រុមសិស្សថ្នាក់ទី៤-៦ ច្រើនជាងក្រុមសិស្សថ្នាក់ទី១-៣។

### ២) គោលបំណង

- លើកទឹកចិត្ត និងធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការអាន
- លើកកម្ពស់ការអានដោយម្ចាស់ការរបស់កុមារ
- ផ្តល់ឱកាសដល់សិស្ស បានអានសៀវភៅតាមជម្រើសរបស់ខ្លួន
- លើកកម្ពស់ទម្លាប់នៃការអាន។

### ៣) ដំណើរការសកម្មភាពអំណានបុគ្គល

#### ក) លំនាំគោលនៃការធ្វើសកម្មភាពអំណានបុគ្គល

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅតាមកម្រិតអានរបស់កុមារ |

**ក-១ កិច្ចស្វាគមន៍ និងការណែនាំ** ២-៣ នាទី | ក្រុមធំ

- ធ្វើការស្វាគមន៍ដល់សិស្ស ដែលបានមកបណ្ណាល័យ
- រំឭកសិស្សអំពីគោលការណ៍បណ្ណាល័យ
- ណែនាំប្រាប់សិស្ស អំពីសកម្មភាពអំណានដែលត្រូវធ្វើក្នុងថ្ងៃនេះ

**ក-២ មុនពេលអាន** ៣-៥ នាទី | ក្រុមធំ

1. ឱ្យសិស្ស ៣នាក់ ចង្អុល និងប្រាប់ឈ្មោះកម្រិតសៀវភៅផ្សេងៗនៅលើធ្នើរ។
2. រំឭកប្រាប់ដល់សិស្ស ឱ្យសួរគ្រូ ឬសិស្សឯទៀត នៅពេលពួកគេត្រូវការឱ្យជួយ។
3. ឱ្យក្រុមសិស្ស ៦ទៅ៨នាក់ម្តងក្នុង១វេន ទៅជ្រើសរើសសៀវភៅដើម្បីអាន។

**ក-៣ ពេលអាន** ១៥-២០ នាទី | បុគ្គល

1. សិស្សចាប់ផ្តើមអង្គុយអានរៀងខ្លួន តាមទីកន្លែងដែលខ្លួនពេញចិត្ត។
2. គ្រូដើរសម្របសម្រួល និងពិនិត្យមើលថា សិស្សកំពុងអានសៀវភៅ។

3. គ្រូស្តាប់សិស្សអាន និងសរសើរដល់ការខំប្រឹងប្រែងរបស់សិស្ស។
4. គ្រូប្រើតេស្តម្រាមដៃ៥ ដើម្បីពិនិត្យកម្រិតអានរបស់សិស្ស ដែលមើលទៅកំពុងមានការលំបាកក្នុងការអាន។ ណែនាំឱ្យសិស្សនោះទៅជ្រើសរើសសៀវភៅ ១ក្បាលផ្សេងទៀត ដែលមានកម្រិតងាយជាង ប្រសិនបើចាំបាច់។
5. គ្រូពិនិត្យមើលរបៀបដែលកុមារកំពុងបើកសន្លឹកសៀវភៅ ហើយជួយពួកគេឱ្យបើកសន្លឹកឱ្យបានត្រឹមត្រូវ ប្រសិនបើចាំបាច់។

## ក-៤ ក្រោយពេលអាន

៥-៧ នាទី | ក្រុមធំ

1. ឱ្យសិស្សកាន់សៀវភៅរបស់ពួកគេ ហើយមកអង្គុយយ៉ាងស្ងៀមស្ងាត់នៅកន្លែងប្រមូលផ្តុំ។
2. ឱ្យសិស្ស ៣ទៅ៤នាក់ ចែករំលែករឿងរ៉ាវអំពីសៀវភៅរបស់ពួកគេ។

   សម្រាប់សិស្សនីមួយៗ គ្រូសួរ១ទៅ២សំណួរ ក្នុងចំណោមសំណួរដូចខាងក្រោម៖
   - តើអ្នកចូលចិត្តរឿងដែលអ្នកអានឬទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
   - តើតួអង្គណាមួយ នៅក្នុងរឿង ដែលអ្នកចូលចិត្ត? ហេតុអ្វី?
   - តើរឿងនេះកើតឡើងនៅឯណា?
   - តើអ្នកចាប់អារម្មណ៍ចំណុចណាមួយជាងគេដែលបានកើតឡើងក្នុងរឿង?
   - តើផ្នែកណាដែលអ្នកពេញចិត្តនៅក្នុងរឿងនេះ? ហេតុអ្វី?
   - ប្រសិនបើអ្នកជា...(តួអង្គ)... តើអ្នកគួរធ្វើអ្វីខុសពីនេះទេ?
   - តើអ្វីដែលគួរឱ្យអស់សំណើចនៅក្នុងរឿងនេះ? ភ័យខ្លាច? សប្បាយរីករាយ? ទុក្ខព្រួយ?
   - តើអ្នកចង់ណែនាំរឿងនេះទៅមិត្តរួមថ្នាក់ដែរ ឬទេ? តើអ្នកគិតថាសិស្សផ្សេងទៀតចូលចិត្តអានវាទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
   - តើអ្នកគិតថា ហេតុអ្វីបានជាអ្នកនិពន្ធសរសេររឿងនេះ?

   អរគុណដល់សិស្សសម្រាប់ការចែករំលែក អំពីសៀវភៅរបស់អ្នក។

3. ឱ្យកុមារយកសៀវភៅទៅទុកនៅលើធ្នើរវិញ

*ប្រសិនបើសល់ពេលឱ្យកុមារ៖*

- ➢ *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីច)*
- ➢ *អានសៀវភៅ ឬខ្ចីសៀវភៅយកទៅផ្ទះ។*

## ខ) លំនាំលម្អិតនៃការធ្វើសកម្មភាពអំណានបុគ្គល

**រយៈពេល៖ ៤០នាទី**

| | |
|---|---|
| | សៀវភៅតាមកម្រិតអានរបស់កុមារ |

### ខ-១ កិច្ចស្វាគមន៍ និងការណែនាំ

២-៣ នាទី | ក្រុមធំ

អង្គុយនៅលើកៅអី ហើយសិស្សអង្គុយលើឥដ្ឋនៅជិតអ្នកជាពាក់កណ្តាលរង្វង់។

ធ្វើការស្វាគមន៍ដល់សិស្សដែលបានមកបណ្ណាល័យ។ រំឭកពួកគេពីគោលការណ៍បណ្ណាល័យ តាមម៉ោងនីមួយៗ រហូតដល់សិស្សស្គាល់ច្បាស់អំពីគោលការណ៍។

ផ្តល់ព័ត៌មានដល់សិស្ស អំពីសកម្មភាពអំណានដែលត្រូវធ្វើ។

**ថ្ងៃនេះយើងនឹងធ្វើសកម្មភាពអំណានបុគ្គល។**

### ខ-២ មុនពេលអាន

៣-៥ នាទី | ក្រុមធំ

SAY **ថ្ងៃនេះ ប្អូននឹងមានពេលអានដោយខ្លួនឯង។ ប្អូននឹងអាចជ្រើសរើសសៀវភៅ១ក្បាល ដែលប្អូនពេញចិត្តយកមកអាន ខ្ញុំនឹងដើរមើលពេលប្អូនអាន។ ប្រសិនបើប្អូនមានការពិបាកអានពាក្យឬឈ្មោះ ណាមួយ ប្អូនអាចប្រាប់មកខ្ញុំឱ្យជួយ។ នៅពេលដែលប្អូនអានចប់សៀវភៅ១ក្បាល ប្អូនអាចទៅយកសៀវភៅ១ក្បាលទៀតមកអាន។**

1. ឱ្យសិស្ស ៣នាក់ ចង្អុល និងប្រាប់ឈ្មោះកម្រិតសៀវភៅផ្សេងៗនៅលើធ្នើរ។

   **តើអ្នកអាចចាំកន្លែងត្រូវជ្រើសរើសសៀវភៅដែលអ្នកអាចអានបានទេ?** ឱ្យសិស្ស ៣នាក់ចង្អុលទៅកម្រិតផ្សេងៗ ហើយសិស្សនៅសល់មើលសិស្សទាំងបីចង្អុល៖ **ចង្អុលទៅកម្រិត ..........** **ចង្អុលទៅកម្រិត ..... ចង្អុលទៅកម្រិត ....។**

2. រំឭកប្រាប់ដល់សិស្ស ឱ្យសួរគ្រូ ឬសិស្សឯទៀត នៅពេលពួកគេត្រូវការឱ្យជួយ។

   **ប្រសិនបើប្អូនជួបពាក្យពិបាកមិនចេះអាន ប្អូនអាចមកសួរខ្ញុំ ឬសួរមិត្តភក្តិដែលនៅជិតប្អូន។**

3. ឱ្យក្រុមសិស្ស ៦ទៅ៨នាក់ម្តងក្នុង១វេន ទៅជ្រើសរើសសៀវភៅដើម្បីអាន។

   **ឱ្យសិស្ស៦ទៅ៨នាក់ក្រោកឈរ ទៅយកសៀវភៅដែលអ្នកចង់អាន។ បន្ទាប់មករកកន្លែងដែលស្ងាត់អង្គុយចុះហើយអាន។ យើងនឹងអានប្រហែល១៥ទៅ ២០នាទី។**

   នៅពេលដែលសិស្សទាំងនោះរើសសៀវភៅបាន ឱ្យសិស្ស១ក្រុមទៀតដែលមានគ្នាពី៦ទៅ៨នាក់ទៅជ្រើសរើសម្តង។ បន្តធ្វើបែបនេះរហូតដល់សិស្សទាំងអស់បានជ្រើសរើសសៀវភៅ ។

ប្រសិនបើសិស្សណាមានបញ្ហាក្នុងការជ្រើសរើសសៀវភៅ ឱ្យសិស្សឯទៀតដែលមានសៀវភៅចាប់ផ្តើមអាន។ គ្រូជួយសិស្សដែលមានបញ្ហា ដោយសួរថាសៀវភៅប្រភេទណាដែលគេចង់អាន។ ជួយពួកគេរកសៀវភៅប្រភេទនោះ។ ប្រសិនបើសិស្សនៅតែមិនដឹងថាត្រូវជ្រើសរើសសៀវភៅប្រភេទណា អ្នកគួរជ្រើសរើសសៀវភៅមួយក្បាលដែលអ្នកគិតថាពួកគេនឹងចូលចិត្តវា។

## ខ-៣ ពេលអាន

១៥-២០ នាទី | ដៃគូ

1. សិស្សចាប់ផ្តើមអង្គុយអានរៀងខ្លួន តាមទីកន្លែងដែលខ្លួនពេញចិត្ត។
2. គ្រូដើរសម្របសម្រួល និងពិនិត្យមើលថា សិស្សកំពុងអានសៀវភៅ។
3. គ្រូស្តាប់កុមារអាន និងសរសើរដល់ការខំប្រឹងប្រែងរបស់កុមារ។
4. គ្រូប្រើតេស្តម្រាមដៃ៥ ដើម្បីពិនិត្យកម្រិតអានរបស់សិស្ស ដែលមើលទៅកំពុងមានការលំបាកក្នុងការអាន។ ណែនាំឱ្យសិស្សនោះទៅជ្រើសរើសសៀវភៅ ១ក្បាលផ្សេងទៀត ដែលមានកម្រិតងាយជាង ប្រសិនបើចាំបាច់។
5. គ្រូពិនិត្យមើលរបៀបដែលកុមារកំពុងបើកសន្លឹកសៀវភៅ ហើយជួយពួកគេឱ្យបើកសន្លឹកឱ្យបានត្រឹមត្រូវ ប្រសិនបើចាំបាច់។

## ខ-៤ ក្រោយពេលអាន

៥-៧ នាទី | ក្រុមធំ

នៅពេលអស់ម៉ោង បញ្ចប់ការអានជាបុគ្គល។

**ឥឡូវនេះ អស់ម៉ោងអានហើយ។ ប្រសិនបើអ្នកចូលចិត្ត ហើយចង់អានសៀវភៅរបស់អ្នកបន្ត អ្នកអាចខ្ចីវាទៅអាននៅផ្ទះ។**

1. ឱ្យសិស្សកាន់សៀវភៅរបស់ពួកគេ ហើយមកប្រមូលផ្តុំអង្គុយយ៉ាងស្ងៀមស្ងាត់នៅកន្លែងដើម។
**ឥឡូវសូមនាំយកសៀវភៅដែលអ្នកបានអានហើយ មកអង្គុយនៅទីនេះ។**

2. ឱ្យសិស្ស៣ទៅ៤នាក់ ចែករំលែករឿងរ៉ាវអំពីសៀវភៅរបស់ពួកគេ។
**តើប្អូនណាស្ម័គ្រចិត្តចែករំលែករឿងរ៉ាវអំពីសៀវភៅ ដែលប្អូនបានអាន?**

សម្រាប់សិស្សនីមួយៗ សួរ១ទៅ២សំណួរ ក្នុងចំណោមសំណួរដូចខាងក្រោម៖

- តើអ្នកចូលចិត្តរឿងដែលអ្នកអានឬទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
- តើតួអង្គណាមួយ នៅក្នុងរឿង ដែលអ្នកចូលចិត្ត? ហេតុអ្វី?
- តើរឿងនេះកើតឡើងនៅឯណា?
- តើអ្នកចាប់អារម្មណ៍ចំណុចណាមួយជាងគេដែលបានកើតឡើងក្នុងរឿង?
- តើផ្នែកណាដែលអ្នកពេញចិត្តនៅក្នុងរឿងនេះ? ហេតុអ្វី?
- ប្រសិនបើអ្នកជា...(តួអង្គ)... តើអ្នកគួរធ្វើអ្វីខុសពីនេះទេ?

- តើអ្វីដែលគួរឱ្យអស់សំណើចនៅក្នុងរឿងនេះ? ភ័យខ្លាច? សប្បាយរីករាយ? ទុក្ខព្រួយ?
- តើអ្នកចង់ណែនាំរឿងនេះទៅមិត្តរួមថ្នាក់ដែរ ឬទេ? តើអ្នកគិតថាសិស្សផ្សេងទៀតចូលចិត្តអានវាទេ? ហេតុអ្វីចូលចិត្ត/មិនចូលចិត្ត?
- តើអ្នកគិតថា ហេតុអ្វីបានជាអ្នកនិពន្ធសរសេររឿងនេះ?

អរគុណដល់សិស្សសម្រាប់ការចែករំលែក អំពីសៀវភៅរបស់អ្នក។

3. ឱ្យកុមារយកសៀវភៅទៅទុកនៅលើធ្នើរវិញ

**ឥឡូវនេះការធ្វើអំណានយើងចប់ហើយ សូមប្អូនៗយកសៀវភៅទៅទុកលើធ្នើរវិញ ហើយដាក់វានៅកន្លែងដើមវិញ។**

*ប្រសិនបើសល់ពេលឱ្យកុមារៈ*

- *គូររូប ហើយសរសេរអំពីរឿងនោះ (បង្កើតសម្ភារព្រីនរីដ)*
- *អានសៀវភៅ ឬខ្ចីសៀវភៅយកទៅផ្ទះ។*

Room to Read®

Sipar